WWF-Cambodia

21, Street 322,
Boeung Keng Kang I,
Phnom Penh, Cambodia
P.O. Box: 2467

Tel: +855 23 218 034
Fax: +855 23 211 909

www.wwf.org.kh
www.panda.org/greatermekong
wwfcambodia@wwf.org.kh

for a living planet®

សេចក្តីប្រកាសសារព័ត៌មាន

សម្រាប់ចេញផ្សាយបន្ទាន់

# អាជីវកម្មសត្វព្រៃគំរាមកំហែងដល់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងបង្កហានិភ័យនៃការចម្លងមេរោគពីសត្វទៅមនុស្ស

របាយការណ៍ថ្មីមួយរបស់អង្គការ WWF បានក្រើនរំលឹកថា ការដាក់អន្ទាក់បានក្លាយជាវិបត្តិ និងបង្កហានិភ័យធ្ងន់ធ្ងរដល់សត្វព្រៃដែលកំពុងរស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាបង្កហានិភ័យនៃការចម្លងមេរោគពីសត្វទៅមនុស្សថែមទៀតផង។ តាមរយៈរបាយការណ៍នេះ វាជាលើកដំបូងហើយដែលគេបានប៉ាន់ប្រមាណអំពីចំនួនអន្ទាក់នៅក្នុងតំបន់ការពារធម្មជាតិដែលស្ថិតក្នុងប្រទេសមួយចំនួនក្នុងតំបន់ ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។

ផ្អែកលើរបាយការណ៍ដែលមានចំណងជើងថា៖ "វិបត្តិនៃការដាក់អន្ទាក់ក្នុងតំបន់អាស៊ីអាគ្នេយ៍ ឬ Silence of the Snares: Southeast Asia's Snaring Crisis" គេបានប៉ាន់ប្រមាណថា មានអន្ទាក់ចំនួនប្រមាណ ១២,៣ លាន កំពុងគំរាមកំហែងដល់ការរស់រានរបស់សត្វព្រៃនៅក្នុងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម។

ភាគច្រើននៃអន្ទាក់ទាំងនេះត្រូវបានផលិត និងច្នៃឡើងដោយប្រើខ្សែ ឬខ្សែកាប។ ការដាក់អន្ទាក់បង្កើនឱកាសដល់មនុស្សក្នុងការប៉ះពាល់ដោយផ្ទាល់នឹងសត្វព្រៃ ដែលវាជាទង្វើអាចបង្កលទ្ធភាពនៃការចម្លងមេរោគពីសត្វទៅមនុស្ស។ ជាក់ស្តែង ក្រុមអ្នកស្រាវជ្រាវបានរកឃើញថាសត្វជ្រូកព្រៃ សំពោច និងសត្វពង្រូលស្ថិតក្នុងចំណោមសត្វច្រើនប្រភេទទៀតដែលជាគោលដៅនៃការដាក់អន្ទាក់ ហើយសុទ្ធសឹងជាប្រភេទសត្វដែលបង្កហានិភ័យខ្ពស់បំផុតនៃការចម្លងមេរោគ។

លោក Stuart Chapman ប្រធានកម្មវិធីសត្វខ្លាប្រចាំតំបន់នៃអង្គការ WWF មានប្រសាសន៍ថា៖ "អន្ទាក់បានសម្លាប់និងបង្ករបួសធ្ងន់ធ្ងរដល់ជីវិតសត្វព្រៃដោយមិនរើសប្រភេទឡើយ។ អន្ទាក់នេះហើយដែលបាន និងកំពុងបំផ្លាញជីវិតសត្វព្រៃសំខាន់ៗនៅក្នុងតំបន់ចាប់តាំងពីប្រភេទសត្វធំៗដូចជា សត្វខ្លាធំ និងសត្វដំរីអាស៊ី រហូតដល់សត្វពង្រូល និងសត្វសំពោច ហើយបន្ថែមលើនេះ វាឈានទៅធ្វើឱ្យតំបន់ព្រៃទាំងមូលលែងមានវត្តមានសត្វព្រៃទៀតផង"។ លោកបន្តថា៖ "សត្វព្រៃអាចបន្តរស់រានបាន លុះត្រាតែរដ្ឋាភិបាលនៃបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ចាត់វិធានការបន្ទាន់ចំពោះវិបត្តិអន្ទាក់នេះ"។

តម្រូវការសាច់សត្វព្រៃនិងផលិតផលសត្វព្រៃរបស់មនុស្សរស់នៅតំបន់ទីក្រុងសម្រាប់ភាពស៊ីវិល័យជាកត្តាជម្រុញឱ្យការដាក់អន្ទាក់ដើម្បីចាប់សត្វព្រៃកើនឡើង ហើយបានបង្កហានិភ័យដល់ថនិកសត្វរស់នៅលើគោកក្នុងតំបន់ប្រមាណជាង ៧០០ ប្រភេទ ក្នុងនោះរួមមានសត្វសំខាន់ៗដែលជាប្រភេទកំពុងរងគ្រោះថ្នាក់បំផុតក្នុងតំបន់ដូចជាសត្វដំរីអាស៊ី សត្វខ្លាធំ សត្វទន្សោង និងរមាំងជាដើម។

របាយការណ៍ដដែលបានបង្ហាញថាមានអន្ទាក់សរុបចំនួន ២៣៤.២៩១ ត្រូវបានដោះនិងប្រមូលចេញពីក្នុងតំបន់ការពារធម្មជាតិចំនួន ៥ នៅក្នុងប្រទេសកម្ពុជា គិតចាប់ពីឆ្នាំ២០១០ មកទល់ឆ្នាំ ២០១៩។

លោក **សេខ ឡៀក** នាយកអង្គការ WWF កម្ពុជា បានមានប្រសាសន៍ថា៖“អន្ទាក់ជាកត្តាគំរាមកំហែងចម្បងចំពោះការរស់រានរបស់សត្វខ្លាធំនៅក្នុងតំបន់ ហើយវាក៏ជាកត្តារួមចំណែកដ៏ធំមួយដល់ការដែលគេសន្មត់ថាសត្វខ្លាធំនេះបានបាត់បង់ទៅហើយពីក្នុងព្រៃធម្មជាតិក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម”។

វិបត្តិអន្ទាក់នេះក៏ជាកត្តាសំខាន់មួយដែលនាំឱ្យមានការថយចុះនូវចំនួនប្រភេទសត្វស៊ីសាច់ជាអាហារមួយចំនួនទៀតដែរនៅក្នុងតំបន់ការពារធម្មជាតិ ដែលគាំទ្រដោយអង្គការ WWF ដូចជាសត្វខ្លារខិន ខ្លាពពក និងសត្វឆ្កែព្រៃ ព្រមទាំងប្រភេទសត្វជាចំណីរបស់ពួកវាដូចជា ទន្សោង ឈ្លូស ជ្រូកព្រៃ ខ្ទីង រមាំង និងសត្វប្រើស។

លោក **សេខ ឡៀក** មានប្រសាសន៍ថា៖“ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ដោយមន្ត្រីឧទ្យានុរក្សនិងមន្ត្រីអនុវត្តច្បាប់ទាំងអស់នៃក្រសួងបរិស្ថាននិងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ហើយខ្ញុំក៏មានក្តីត្រេកអរចំពោះការដាក់ចេញនូវសេចក្តីណែនាំលេខ ៥ របស់អភិបាលខេត្តមណ្ឌលគិរីឆ្នាំ ២០១៩ ដែលហាមឃាត់ការទិញការលក់ ការដឹកជញ្ជូន ការប្រើប្រាស់ផលិតផលសត្វព្រៃ និងការបរិភោគសាច់សត្វព្រៃ ហើយបានឈានទៅផ្តល់ផលវិជ្ជមានក្នុងការកាត់បន្ថយនូវចរាចរសាច់សត្វព្រៃនៅតាមទីផ្សារនិងភោជនីយដ្ឋានក្នុងមូលដ្ឋាន”។

យ៉ាងណាក៏ដោយ លោក **សេខ ឡៀក** បន្ថែមទៀតថា៖“អន្ទាក់នៅតែជាក្តីបារម្ភចំបងចំពោះការរស់រានរបស់សត្វព្រៃ។ ហើយការដកអន្ទាក់ចេញពីព្រៃតែមួយមុខនៅមិនទាន់គ្រប់គ្រាន់ទេ។ ការពង្រឹងបទបញ្ញត្តិច្បាប់បន្ថែមទៀត ការបង្កើនប្រសិទ្ធភាពក្នុងអនុវត្តនីតិវិធីតុលាការ និងការដាក់ទោសទណ្ឌឱ្យធ្ងន់ធ្ងរដល់ជនល្មើសច្បាប់ សុទ្ធសឹងជាតម្រូវការចាំបាច់ណាស់ដើម្បីបញ្ចប់ការធ្វើពាណិជ្ជកម្មសត្វព្រៃដែលជាគោលដៅនៃការដាក់អន្ទាក់ ជាពិសេសពពួកថនិកសត្វមានក្រចកជើងចំពាម ពពួកបក្សី និងពពួកល្មូនផ្សេងទៀតដែលមានហានិភ័យខ្ពស់ក្នុងការចម្លងមេរោគដល់មនុស្ស។

វិបត្តិបង្កដោយ កូវីដ១៩ បានបង្ហាញឱ្យឃើញថា ត្រូវតែមានការផ្លាស់ប្តូរជាលក្ខណៈប្រព័ន្ធ ដើម្បីដោះស្រាយកត្តាចលករដែលនាំឱ្យមានការរាលដាលជំងឺជាសកល។ នៅក្នុងសោកនាដកម្មនេះ ក៏មានកាលានុវត្តភាពមួយសម្រាប់ផ្សះផ្សាទំនាក់ទំនងរបស់មនុស្សជាមួយធម្មជាតិឡើងវិញ និងដើម្បីបន្ធូរបន្ថយហានិភ័យនៃការរាលដាលជំងឺផ្សេងទៀតនាពេលអនាគត។ យ៉ាងណាក៏ដោយ អនាគតប្រសើរមួយអាចចាប់ផ្តើមទៅរួច ទាល់តែរដ្ឋាភិបាលនានា បណ្តាក្រុមហ៊ុន និងប្រជាជនរស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងនោះមានប្រទេសកម្ពុជាផងដែរ ចាប់ផ្តើមធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវពីថ្ងៃនេះទៅ។

អង្គការ WWF កំពុងអំពាវនាវជាសកលឱ្យមានការទទួលស្គាល់និងអនុវត្តគោលការណ៍ សុខភាពតែមួយ ‘One Health’ ដោយផ្សារភ្ជាប់សុខភាពរបស់មនុស្ស សត្វ និងបរិស្ថាន ដែលយើងពឹងអាស្រ័យរួមគ្នា ហើយទទូចសុំឱ្យគោលការណ៍នេះត្រូវបានដាក់បញ្ចូលទៅក្នុងការធ្វើសេចក្តីសម្រេចស្តីពីសត្វព្រៃ និងការប្រើប្រាស់ដីធ្លី។ គោលការណ៍នេះក៏គួរត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីសម្រេចនានាផ្នែកធុរកិច្ចនិងហិរញ្ញវត្ថុផងដែរ ជាពិសេសសេចក្តីសម្រេចពាក់ព័ន្ធនឹងសុខភាពពិភពលោក”។

*************************

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក ទេព អស្នារិទ្ធ ប្រធានកិច្ចការសាធារណៈ និងគ្រប់គ្រងព័ត៌មាននៃអង្គការ WWF-កម្ពុជា

អ៊ីម៉េល៖ asnarith.tep@wwf.org.kh  ទូរស័ព្ទ៖ ០១២ ៩៥៧ ៩១៩

**ព័ត៌មានសម្រាប់អ្នកនិពន្ធ៖**

សូមអានរបាយការណ៍ទាំងស្រុង ដោយទាញយករបាយការណ៍ពីតំណរនេះ៖ https://wwf.to/3f8rzTb

សូមទាញយករូបភាពតាមរយៈតំណរនេះ៖ https://rb.gy/xww248

**អំពីWWF**

អង្គការមូលនិធិសកលសម្រាប់ធម្មជាតិ (WWF) ជាអង្គការអភិរក្សធម្មជាតិឯករាជ្យមួយ ដែលមានអ្នកគាំទ្រជាង៣០លាននាក់ និងមានបណ្ដាញបេសកកម្មនៅក្នុង១០០ប្រទេសលើពិភពលោក។ បេសកកម្មរបស់យើងគឺបញ្ឈប់ការរេចរឹលនៃបរិស្ថានធម្មជាតិរបស់ភពផែនដី និងដើម្បីកសាងអនាគតមួយដែលមនុស្សរស់នៅដោយសុខដុមជាមួយនឹងធម្មជាតិ តាមរយៈការអភិរក្សជីវៈចម្រុះរបស់ពិភពលោក ធានាការប្រើប្រាស់ដោយចីរភាពនូវធនធានកកើតឡើងវិញ និងលើកកម្ពស់ការកាត់បន្ថយការបំពុលនិងការប្រើប្រាស់ខ្ជះខ្ជាយ។

សូមចូលចូលទៅកាន់ទំព័រ Facebook និង Twitter របស់យើងដើម្បីទទួលបាននូវដំណឹងថ្មីៗ និងសូមចូលទៅកាន់គេហទំព័ររបស់យើងគឺ www.wwf.org.kh ដើម្បីទទួលបានព័ត៌មានផ្សេងៗទៀត។